**របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការ**

# ថ្នាំបង្ការជម្ងឺខាន់លឿន

## *អ្វីដែលអ្នកចាំបាច់ត្រូវដឹង*

របាយការណ៍ព័ត៌មានស្តីអំពីថ្នាំបង្ការជា
ច្រើនមានជាភា
សាអេស្ប៉ាញនិងភាសាដទៃទៀត។
សូមមើលនៅក្នុងគេហទំព័រ

## 1 តើអ្វីជាជម្ងឺខាន់លឿន ?

ជម្ងឺខាន់លឿនគឺជាមេរោគយ៉ាងបណ្តាលមកពីវីរុសខាន់លឿន ។ វាត្រូវបានរកឃើញក្នុងតំបន់មួយនៃប្រទេសអាហ្វ្រិក និងប្រទេសអាមេរិចខាងត្បូង ។ ជម្ងឺខាន់លឿនត្រូវបានរីករាលដាលតាមរយៈមូសខាំ ។ វាមិនអាចឆ្លងតាមរយៈការប្រាស្រ័យទាក់ទងរវាងមនុស្ស និងមនុស្សទេ ។ ជាធម្មតា មនុស្សដែលមានមេរោគខាន់លឿនត្រូវសម្រាកក្នុងមន្ទីរពេទ្យ ។ ជម្ងឺខាន់លឿនអាចបណ្តាលឲ្យ៖

- គ្រុនក្តៅ និងមានរោគសញ្ញាដូចជម្ងឺផ្តាសសាយ
- ជម្ងឺខាន់លឿន (ស្បែក ឬភ្នែកឡើងលឿន)
- ឈាមហូរចេញពីរាងកាយច្រើនកន្លែង
- ជម្ងឺថ្លើម ជម្ងឺក្រលៀន ជម្ងឺផ្លូវដង្ហើម និងសរីរាង្គផ្សេងទៀ
- ស្លាប់ (20% - 50% នៃករណីធ្ងន់ធ្ងរ)

## 2 តើខ្ញុំអាចបង្កាជម្ងឺខាន់លឿនដោយរបៀបណា?

**វ៉ាក់សាំងជម្ងឺខាន់លឿន**

ថ្នាំបង្ការជម្ងឺខាន់លឿនអាចបង្ការជម្ងឺខាន់លឿនបាន ។ ជម្ងឺខាន់លឿនត្រូវបានផ្តល់ដោយមជ្ឈមណ្ឌលសិក្សាថ្នាំបង្ការតែប៉ុណ្ណោះ ។ ក្រោយពីទទួលចាក់ថ្នាំថ្នាំបង្ការ អ្នកគួរត្រូវបានទទួល “វិញ្ញាបនបត្រអន្តរជាតិស្តីពីការចាក់ថ្នាំថ្នាំបង្ការ ឬការបង្កាជម្ងឺ” ដែលបោះត្រា និងចុះហត្ថលេខា (កាតលឿន) ។ វិញ្ញាបនបត្រនេះមានសុពលភាព 10 ថ្ងៃ បន្ទាប់ពីការចាក់ថ្នាំ ថ្នាំបង្ការ និងមានប្រសិទ្ធិភាពរយៈពេល 10 ឆ្នាំ ។

**អ្នកនឹងត្រូវការកាតនេះដែលជាភស្តុតាងបញ្ជាក់ពីការចាក់ថ្នាំបង្ការដើម្បីចូលក្នុងប្រទេសណាមួយ ។**

អ្នកធ្វើដំណើរដោយមិនមានភស្តុតាងបញ្ជាក់ត្រូវបានចាក់ថ្នាំបង្ការនៅពេលចូល ឬឃាត់ទុករហូតដល់រយៈពេល 6 ថ្ងៃដើម្បីប្រាកដថាពួកគេគ្មានមេរោគឆ្លង ។ ការរៀបចំកម្មវិធីធ្វើដំណើររបស់អ្នកត្រូវធ្វើឡើងជាមួយគ្រូពេទ្យ ឬគិលានុបដ្ឋាយិកាមុខពេលដែលអ្នកចាក់ថ្នាំបង្ការខាន់លឿន ។ ពិភាក្សានាយកដ្ឋានសុខភាពរបស់ ឬចូលមើលគេហទំព័រស្តីពីព័ត៌មានធ្វើដំណើរ CDC តាម **www.cdc.gov/travel** ដើម្បីស្វែងយល់ពីតម្រូវការនៃថ្នាំបង្ការជម្ងឺខាន់លឿន និងអនុសាសន៍របស់ប្រទេសខុសៗគ្នា ។

**វិធានការបង្កាផ្សេងទៀត**

វិធីផ្សេងទៀតដើម្បីបង្កាជម្ងឺខាន់លឿនគឺត្រូវចៀសវាងពីមូសខាំដោយ៖

- នៅកន្លែងដែលការពារ និងខ្យល់គ្រប់គ្រាន់
- ស្លៀកពាក់សម្លៀកបំពាក់ដែលបិទរាងកាយរបស់អ្នកជិ
- ប្រើប្រាស់ថ្នាំបណ្តេញសត្វល្អិត ដូចជាថ្នាំដែលផ្ទុកសារធាតុ DEET

## 3 វ៉ាក់សាំងជម្ងឺខាន់លឿន ?

ថ្នាំបង្ការជម្ងឺខាន់លឿនគឺវីរុសដែលរស់និងទន់ខ្សោយ ។ វាត្រូវបានផ្តល់ឲ្យដោយការចាក់ ។ សម្រាប់មនុស្សដែលមានហានិភ័យខ្ពស់កម្រិតថ្នាំប្រើប្រាស់បន្ថែមត្រូវបានផ្តល់អនុសាសន៍រៀងរាល់10 ឆ្នាំ ។ ថ្នាំបង្ការជម្ងឺខាន់លឿន អាចត្រូវបានផ្តល់ឲ្យក្នុងពេលតំណាលគ្នាជាមួយនឹងថ្នាំបង្ការផ្សេងទៀតបាន ។

**តើនរណាគួរទទួលបានថ្នាំបង្ការជម្ងឺខាន់លឿន?**

- ក្មេងអាយុ 9 ខែដល់មនុស្សចាស់អាយុ 59 ឆ្នាំដែលធ្វើដំណើរ ឬរស់នៅក្នុងតំបន់ដែលត្រូវបានស្គាល់ថាមានជម្ងឺខាន់លឿនរាលត្បា ឬ អ្នកដែលធ្វើដំណើរចូលប្រទេសដែលតម្រូវឲ្យមានចាក់ថ្នាំបង្ការ ។
- ទីពិសោធន៍បុគ្គលិតដែលអាចនឹងឆ្លងវីរុសខាន់លឿន ឬវីរុសថ្នាំបង្ការ

ព័ត៌មានសម្រាប់អ្នកធ្វើដំណើរអាចត្រូវបានរកឃើញតាម CDC **(www.cdc.gov/travel)** អង្គការសុខភាពពិភពលោក **www.who.int)** និងអង្គការសុខភាពអាមេរិចប៉ាន (**www.paho.org**)

អ្នកមិនគួរផ្តល់ឈាមក្នុងរយៈពេល 14 ថ្ងៃក្រោយពីចាក់ថ្នាំបង្ការនោះទេ ពីព្រោះមានហានិភ័យនៃការឆ្លងនៃវុសីសតាមរយៈឈាម ។

## 4 តើនរណាមិនគួរទទួលបានថ្នាំបង្ការខាន់លឿន?

- នរណាម្នាក់មានប្រតិកម្មធ្ងន់ធ្ងរ (គម្រោមគំហែងដល់អាយុជីវិត) ជាមួយនឹងសារធាតុថ្នាំបង្ការ រួមមានស៊ុត ប្រតេអ៊ីតសាច់មាន់ ឬជាតិស្ករ ឬអ្នកដែលមានប្រតិកម្មជាមួយកម្រិតថ្នាំប្រើប្រាស់ពីមុននៃថ្នាំបង្ការខាន់លឿនយ៉ាងខ្លាំងមិនគួរទទួលថ្នាំបង្ការខាន់លឿននោះទេ ។ *ប្រាប់វេជ្ជបណ្ឌិតរបស់អ្នកប្រសិនជាអ្នកមានប្រតិកម្មធ្ងន់ធ្ងរណាមួយ ។*
- ទារកមានអាយុតិចជាង 6 ខែមិនគួរទទួលបានថ្នាំបង្ការនោះទេ ។
- ប្រាប់វេជ្ជបណ្ឌិតរបស់អ្នកប្រសិនជា៖
  - អ្នកមានមេរោគ HIV/AIDS ឬមេរោគផ្សេងទៀតដែលប៉ះពាល់ដល់ប្រព័ន្ធការពាររាងកាយ ។
  - ប្រព័ន្ធការពាររាងកាយរបស់អ្នកគឺទន់ខ្សោយបណ្តាលមកពីមហារីក ឬស្ថានភាពព្យាបាលផ្សេងទៀត បន្សាំសរីរាង្គ ឬការប្រើកាំរស្មីវិទ្យសកម្មព្យាបាលជម្ងឺមហារីក ឬការព្យាបាលដោយប្រើប្រាស់ថ្នាំ (ដូចជាស្តេរ៉ូអ៊ីការព្យាបាលជម្ងឺដោយប្រើថ្នាំ ឬជាតិគីមី ឬថ្នាំផ្សេងទៀតដែលប៉ះពាល់ដល់មុខងារកោសិការការពាររាងកាយ) ។



U.S. Department of Health and Human Services
Centers for Disease Control and Prevention

  - ក្រពេញអង់ដូគ្រីននៅក្រោយឆ្អឹងសន្ទះទ្រូងរបស់អ្នកត្រូវបានយកចេញ ឬអ្នកមានជម្ងឺក្រពេញអង់ដូគ្រីន ដូចជា myasthenia gravis រោគសញ្ញា DiGeorge ឬ thymoma ។

វេជ្ជបណ្ឌិតរបស់អ្នកនឹងជួយអ្នកក្នុងការសម្រេចចិត្តប្រសិនជាអ្នកអាចទទួលថ្នាំបង្ការ ឬក៏អត់ ។

- មនុស្សពេញវ័យអាយុ 60 ឆ្នាំ និងចំណាយជាងនេះមិនអាចចៀសវាងពីការធ្វើដំណើរទៅតំបន់រាលត្បាលដោយជម្ងឺខាន់លឿនគួរប្រឹក្សាជាមួយវេជ្ជបណ្ឌិត ។ ពួកគាត់អាចមានហានិភ័យបញ្ហាធ្ងន់ធ្ងរក្រោយពីទទួលថ្នាំបង្ការ ។
- ទារកអាយុ 6 ខែដល់ 8 ខែ ស្ត្រីមានទម្ងន់ និងគួរចៀសវាស់ ឬម្តាយកំពុងបំបៅដោះកូន គួរចៀសវាង ឬផ្អាកការធ្វើដំណើរទៅតំបន់មានជម្ងឺខាន់លឿន ។ ប្រសិនជាការធ្វើដំណើរមិនអាចចៀសវាងបាន សូមប្រឹក្សាជាមួយវេជ្ជបណ្ឌិតរបស់អ្នក ។

ប្រសិនជាអ្នកមិនអាចទទួលថ្នាំបង្ការដោយសារមូលហេតុការព្យាបាល ប៉ុន្តែតម្រូវឲ្យមានភស្តុតាងនៃថ្នាំបង្ការជម្ងឺខាន់លឿនសម្រាប់ការធ្វើដំណើរ វេជ្ជបណ្ឌិតរបស់អ្នកអាចផ្តល់ឲ្យអ្នកនូវ**លិខិតលើកលែង** ប្រសិនជាគាត់គិតថាហានិភ័យទាបក្នុងការទទួលយក ។ ប្រសិនជាអ្នកមានគម្រោងប្រើប្រាស់ការលើកលែង អ្នកគួរទាក់ទងទៅស្ថានទូតនៃប្រទេសដែលអ្នកមានគម្រោងទៅទស្សនកិច្ចសម្រាប់ព័ត៌មានបន្ថែម ។

## 5 | តើអ្វីជាហានិភ័យពីថ្នាំបង្ការជម្ងឺខាន់លឿន?

ថ្នាំបង្ការ ដូចថ្នាំនានាអាចបណ្តាលឲ្យមានប្រតិកម្មធ្ងន់ធ្ងរ ។ ប៉ុន្តែហានិភ័យនៃថ្នាំបង្ការដែលបណ្តាលឲ្យប៉ះពាល់ធ្ងន់ធ្ងរ ឬស្លាប់គឺមានកម្រិតទាបខ្លាំង ។

**បញ្ហាមិនធ្ងន់ធ្ងរ**

វ៉ាំងសាំងខាន់លឿនគឺទាក់ទងនឹងការក្តៅខ្លួន និងការឈឺចាប់ ដំបៅ ក្រហម ឬហើមនៅកន្លែងដែលត្រូវបានចាក់ ។ បញ្ហាទាំងនេះកើតឡើងលើមនុស្ស 1 នាក់ក្នុងចំណោម 4 នាក់ ។ ជាធម្មតា ពួកគាត់ចាប់ផ្តើមភ្លាមៗបន្ទាប់ពីចាក់ថ្នាំ និងអាចពន្យារហូតដល់មួយសប្តាហ៍

**បញ្ហាធ្ងន់ធ្ងរ**

- ប្រតិកម្មធ្ងន់ធ្ងរទៅនឹងសារធាតុថ្នាំបង្ការ (ប្រហែលជា 1 នាក់ក្នុងចំណោម 55,000 នាក់) ។
- ប្រតិកម្មប្រព័ន្ធប្រសាទធ្ងន់ធ្ងរ (ប្រហែលជា 1 នាក់ក្នុងចំណោម 125,000 នាក់) ។
- ជម្ងឺធ្ងន់ធ្ងរដែលប៉ះពាល់ដល់អាយុជីវិតដោយសរីរាង្គចុះខ្សោយ (ប្រហែលជា 1 នាក់ក្នុងចំណោម 250,000 នាក់) ។ ច្រើនជាងពាក់កណ្តាលមនុស្សស្លាប់ដោយសារការប្រតិកម្មនេះ ។

ញ្ហាពីរចុងក្រោយនេះមិនត្រូវបានរាយការណ៍បន្ទាប់ពីការបន្ថែមកម្រិតថ្នាំប្រើ ។

## 6 | តើប្រសិនជាមានប្រតិកម្មធ្ងន់ធ្ងរ?

**តើអ្វីដែលខ្ញុំគួរស្វែងរក?**

- ស្វែងរកអ្វីណាមួយដែលធ្វើឲ្យអ្នកព្រួយបារម្ភ ដូចជាសញ្ញានៃប្រតិកម្មធ្ងន់ធ្ងរ ក្តៅខ្លួនខ្លាំង ផ្លាស់ប្តូរអត្តចរិត ឬមានរោគសញ្ញាដូចជម្ងឺផ្តាសសាយដែលកើតឡើងពី 1-30 ថ្ងៃក្រោយពីចាក់ថ្នាំបង្ការ ។ សញ្ញានៃប្រតិកម្មធ្ងន់ធ្ងរអាចរួមមានផ្លូតជាច្រើននៅលើស្បែក ហើមមុខ និងក ពិបាកដកដង្ហើម ចង្វាក់បេះដូងលោតលឿន វិលមុខ និងខ្សោយ ។ ទាំងនេះចាប់ផ្តើមប៉ុន្មានម៉ោងបន្ទាប់ពីចាក់ថ្នាំបង្ការរួច ។

**តើអ្វីដែលខ្ញុំធ្វើ?**

- ប្រសិនជាអ្នកគិតថាវាគឺជាប្រតិកម្មធ្ងន់ធ្ងរ ឬមានភាពអាសន្នផ្សេងទៀតដែលមិនអាចរងចាំ ទូរស័ព្ទទៅ 9-1-1 ឬនាំអ្នកជម្ងឺមិនកាន់មន្ទីរពេទ្យដែលជិតបំផុត ។ បើមិនដូច្នោះទេ សូមទូរស័ព្ទទៅកាន់វិជ្ជបណ្ឌិតរបស់អ្នក ។
- បន្ទាប់មកទៀត ប្រតិកម្មគួរតែរាយការណ៍ទៅកាន់ប្រព័ន្ធរាយការណ៍ហេតុការណ៍ប្រតិកម្មដោយថ្នាំបង្ការ (VAERS) ។ វេជ្ជបណ្ឌិតរបស់អ្នកអាចដាក់ពាក្យក្នុងការរាយការណ៍នេះ ឬអ្នកអាចរាយការណ៍ដោយខ្លួនឯងផ្ទាល់តាមគេហទំព័រ VAERS មាននៅ **www.vaers.hhs.gov** ឬដោយទូរស័ព្ទទៅលេខ **800-822-7967** ។

*VAERS គឺសម្រាប់រាយការណ៍ពីប្រតិកម្មតែប៉ុណ្ណោះ ។ ពួកគាត់មិនផ្តល់ប្រឹក្សាការព្យាបាលនោះទេ ។*

## 7 | តើខ្ញុំអាចស្វែងយល់បន្ថែមដោយរបៀបណា?

- សួរនាំពីវេជ្ជបណ្ឌិតរបស់អ្នក ។
- ទូរស័ព្ទទៅនាយកដ្ឋានសុខភាពក្នុងតំបន់ ឬរដ្ឋ ។
- ទាក់ទងទៅមជ្ឈមណ្ឌលសម្រាប់ការគ្រប់គ្រង និងបង្កាជម្ងឺ (CDC)៖
  - ទូរស័ព្ទទៅលេខ **1-800-232-4636 (1-800-CDC-INFO)**
  - ចូលទៅគេហទំព័រ CDC មាននៅ
    **www.cdc.gov/travel**
    **www.cdc.gov/yellowfever/** ឬ
    **www.cdc.gov/vaccines/vpd-vac/yf**

Vaccine Information Statement

# Yellow Fever Vaccine

Khmer

3/30/2011

Translation provided by the California Department of Public Health